# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ្នកនាំពាក្យ គ.ជ.ប**

**លេខ ០៤៧ គ.ជ.ប**

ថ្ងៃ សុក្រ ៦រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

## សេចក្តីប្រកាសព័ត៌មាន
## សុក្រឹតភាពនៃបញ្ជីបោះឆ្នោតរបស់ គ.ជ.ប

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ជាថ្ងៃចុងក្រោយនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។ ជាលទ្ធផលគិតត្រឹមម៉ោង ១៨:០០នាទី ប្រជាពលរដ្ឋគ្រប់អាយុ ១៨ឆ្នាំ ដែលបានចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៩ មានចំនួន ១០៨,០៣៩ នាក់ ក្នុងចំណោមប្រជាពលរដ្ឋប៉ាន់ស្មាន ចំនួន ៣៧២,៦២៨ នាក់ ដែលស្មើនឹង ២៨.៩៩% ។ ប្រជាពលរដ្ឋដែលត្រូវលុបចេញពីបញ្ជី មានចំនួន ៤២,៤៤៣ នាក់ កែតម្រូវ ២,០០៦ នាក់ និងផ្ទេរចូល ១៩,០៨៣ នាក់ ។ តួលេខទាំងអស់នេះ គ្រាន់តែជាលទ្ធផលបណ្តោះអាសន្នតែប៉ុណ្ណោះ។

ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនេះ មានការចូលរួមតាមដាន និងសង្កេតមើលយ៉ាងយកចិត្តទុកដាក់ពីគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងនោះរួមមាន ៖

- គណបក្សប្រជាជនកម្ពុជា បានដាក់ភ្នាក់ងារចំនួន ១,៩៨៦ នាក់
- អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ បានដាក់អ្នកសង្កេតការណ៍ចំនួន ១៦ នាក់
- អង្គការខុមហ្វ្រែល បានដាក់អ្នកសង្កេតការណ៍ចំនួន ៨ នាក់ ប៉ុន្តែកំពុងត្រួតពិនិត្យលើពាក្យស្នើសុំ។

ទិន្នន័យបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។ តើបញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពមានសុក្រឹតភាពបែបណា ដើម្បីធានាថា ប្រជាពលរដ្ឋខ្មែរម្នាក់ៗមានឈ្មោះតែមួយគត់ក្នុងបញ្ជីបោះឆ្នោត ហើយការលុបចេញ និងការផ្ទេរឈ្មោះចូល ក្នុងបញ្ជីបោះឆ្នោតមានលក្ខណៈត្រឹមត្រូវ និងច្បាស់លាស់បែបណា?

ដោយមានជំនួយបច្ចេកទេសពីប្រទេសជប៉ុនលើប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតមានពីររបៀប ៖

**ទី១.** នៅពេលទទួលបានទិន្នន័យនៃអ្នកបោះឆ្នោតភ្លាម ទិន្នន័យទាំងនោះ នឹងត្រូវបានផ្ទៀងផ្ទាត់ជាស្វ័យប្រវត្តិដោយម៉ាស៊ីន ជាមួយនឹងប្រព័ន្ធទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលទទួលបានពីក្រសួងមហាផ្ទៃ

**ទី២.** នៅពេលដែលម៉ាស៊ីនច្រានចោលទិន្នន័យដែលពុំមាន ឬខុសពីប្រព័ន្ធទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលទទួលបានពីក្រសួងមហាផ្ទៃ ការផ្ទៀងផ្ទាត់ទិន្នន័យនឹងត្រូវធ្វើឡើងដោយការផ្ទៀងផ្ទាត់

ផ្អែកទៅលើទិន្នន័យ និងរូបថតក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន ដែលបញ្ជូនតាមប្រព័ន្ធកុំព្យូទ័រ ដោយ ក.ច.ប មានន័យថាត្រូវធ្វើឡើងដោយផ្ទាល់ភ្នែករបស់ក្រុមការងារជាច្រើនក្រុម នៃនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត រួចហើយនឹងត្រូវត្រួតពិនិត្យជាចុងក្រោយម្តងទៀត ដោយក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ។ ក្នុងករណីនៅសេសសល់លំអៀងតិចតួច ដែលជៀសមិនផុត គ.ជ.ប បានសហការជាមួយអង្គការ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) ដូចកាលពីឆ្នាំ២០១៨ ដើម្បីកែតម្រូវទិន្នន័យ ប្រសិនបើរកឃើញកំហុសឆ្គង ដើម្បីធានាបានសុក្រឹតភាពនៃបញ្ជីបោះឆ្នោត ។ លើសពីនេះទៀត ប្រសិនបើមានកញ្ចប់ថវិកាក្នុងផែនការថវិកា គ.ជ.ប នឹងជួលក្រុមហ៊ុនឯករាជ្យ ដើម្បីធ្វើសវនកម្មបញ្ជីបោះឆ្នោត ។

ប្រជាពលរដ្ឋគ្រប់រូបក៏អាចចូលរួមបានដែរ ដោយគ្រាន់តែផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនតាមរយៈអាសយដ្ឋាន www.voterlist.kh ដែលបង្ហោះនៅលើគេហទំព័រ គ.ជ.ប និងតាមរយៈ Voterlist KH (App) ហើយបើឃើញខុសឆ្គង អាចស្នើសុំក្រុមចុះឈ្មោះបោះឆ្នោតកែតម្រូវបានភ្លាមៗ ។

សុក្រឹតភាពនៃបញ្ជីបោះឆោត គឺជាការចាំបាច់សម្រាប់អ្នកបោះឆ្នោត ដែលត្រូវជ្រើសរើសមេដឹកនាំ ឬតំណាងរបស់ខ្លួនក្នុងការបោះឆ្នោតមួយលើកៗ ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងអ្នកនាំពាក្យ គ.ជ.ប | ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក និងអ្នកនាំពាក្យ គ.ជ.ប |
| Tel: (855)12 959 666 | Tel: (855)12 518 485 |
| Email : hangputhea@gmail.com | Email : sovannaromhy@yahoo.fr |